**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ១១៧/០៨ **គ.ជ.ប**

**គោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**__កម្មវត្ថុ__** ៖ សំណើសុំជួយអន្តរាគមន៍ទៅគ្រប់ប្រធានក្រុមហ៊ុនសន្តិសុខឯកជននិងប្រធានកាស៊ីណូទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យបុគ្គលិកសន្តិសុខ និង បុគ្គលិកកាស៊ីណូបានទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ អាទិត្យ ទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ។

**__យោង__** ៖ -ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

-ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ ។

តាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជម្រាបឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជ្រាបថា ថ្ងៃ អាទិត្យ ទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ខាងមុខនេះ គឺជាកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីជួយអន្តរាគមន៍ទៅគ្រប់ប្រធានក្រុមហ៊ុនសន្តិសុខឯកជន និង ប្រធានកាស៊ីណូទាំងអស់ ដើម្បីសម្រួលដល់បុគ្គលិកសន្តិសុខឯកជន និងបុគ្គលិកកាស៊ីណូទាំងអស់ដែលបានចុះឈ្មោះបោះឆ្នោត បានទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ តាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៨

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

អ៊ឹម សូស៊ី

**__ចម្លងជូន__**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- ឯកសារ កាលប្បវត្តិ